អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ការបង់ពន្ធជូនរដ្ឋគឺជាកាតព្វកិច្ច របស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប
ដើម្បីចូលរួមចំណែកការពារ និង ការអភិវឌ្ឍន៍មាតុភូមិកម្ពុជា
To Pay Tax Is The Obligation For All Cambodian People And
To Contribute To The Defense And Development Of Our Nation!




# សិក្ខាសាលា
# ស្តីពី
# “ភាតព្វកិច្ចគណនេយ្យនិងសវនកម្ម” និង “បច្ចុប្បន្នភាពនៃច្បាប់ស្តីពីសារពើពន្ធ”

**សហការរៀបចំដោយ**
**ក្រុមប្រឹក្សាជាតិគណនេយ្យ និងអគ្គនាយកដ្ឋានពន្ធដារ**
**រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨**
**សណ្ឋាគារ ភ្នំពេញ**




# បច្ចុប្បន្នភាពច្បាប់ និងបទប្បញ្ញត្តិថ្មីៗ ស្តីពីពន្ធដារ

ថ្ងៃពុធ ១២កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨
សណ្ឋាគារ ភ្នំពេញ

រៀបចំដោយ
អគ្គនាយកដ្ឋានពន្ធដារ

# មាតិកា

១. ពន្ធលើប្រាក់បៀវត្ស (ច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៨)

២. ការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស

៣. កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យធ្វើសវនកម្មគណនេយ្យ

៤. សេចក្តីជូនដំណឹងស្តីពីការកែតម្រូវបញ្ជីគណនេយ្យនិងលិខិតប្រកាសពន្ធ ដោយស្ម័គ្រចិត្ត និងកាតព្វកិច្ចផ្តល់របាយការណ៍សវនកម្មឯករាជ្យ

៥. ពន្ធអប្បបរមា និងលក្ខណវិនិច្ឆ័យនៃការកាន់បញ្ជីគណនេយ្យមិនត្រឹមត្រូវ

៦. ចំណាត់ថ្នាក់នៃអនុលោមភាពសារពើពន្ធ

៧. បទល្មើស និងទោសទណ្ឌ

# ១. ពន្ធលើប្រាក់បៀវត្ស (ច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៨)

មាត្រា៤៧ ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ ត្រូវបានកែសម្រួលដោយមាត្រា ១០ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដូចខាងក្រោម÷

| ភាគបៀវត្សជាប់ពន្ធប្រចាំខែ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | 0 ៛ | ដល់ | ១ ២00 000 ៛ | 0% |
| ពី | ១ ២00 00១ ៛ | ដល់ | ២ 000 000 ៛ | ៥% |
| ពី | ២ 000 00១ ៛ | ដល់ | ៨ ៥00 000 ៛ | ១0% |
| ពី | ៨ ៥00 00១ ៛ | ដល់ | ១២ ៥00 000 ៛ | ១៥% |
| | | លើសពី | ១២ ៥00 000 ៛ | ២0% |

# ២. ការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស

អ្នកជាប់ពន្ធត្រូវបានបែងចែកជា បីប្រភេទ ដូចខាងក្រោម៖

១- **អ្នកជាប់ពន្ធតូច** គឺជាសហគ្រាសឯកបុគ្គល ឬសហគ្រាសសហកម្មសិទ្ធ ដែល៖

ក. មានផលរបរប្រចាំឆ្នាំចាប់ពី ២៥០ លានរៀល ដល់ ៧០០ លានរៀល ឬ

ខ. មានផលរបរក្នុងរយៈពេល បី ខែ ជាប់គ្នាណាមួយ ដែលបញ្ចប់ក្នុងឆ្នាំប្រតិទិនចរន្ត ចាប់ពី ៦០ លានរៀលឡើងទៅ ឬ

គ. រំពឹងថាមានផលរបរក្នុងរយៈពេលបីខែ ជាប់គ្នាខាងមុខ ចាប់ពី ៦០ លានរៀល ឡើងទៅ ឬ

ឃ. ចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ ឬស្នងថ្លៃ ក្នុងការផ្គត់ផ្គង់ទំនិញឬសេវា រួមទាំងភាសី

*(ប្រកាសលេខ០២៥ សហវ.ប្រក.អពដ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨)*

# ២. ការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស(ត)

## ២- អ្នកជាប់ពន្ធមធ្យម គឺជា៖

ក. សហគ្រាសដែលមានផលរបរប្រចាំឆ្នាំចាប់ពី ៧០០ លានរៀល ដល់ ៤ ០០០ លានរៀល ឬ

ខ. សហគ្រាសដែលបានចុះបញ្ជីជានីតិបុគ្គល ការិយាល័យតំណាង ឬ

គ. ស្ថាប័នរដ្ឋថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការឬសមាគមគ្រប់ប្រភេទ រួមទាំងអង្គការមិនមែនរដ្ឋាភិបាល ឬ

ឃ. បេសកកម្មការទូតនិងកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា។

# ២. ការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស(ត)

## ៣- អ្នកជាប់ពន្ធធំ គឺជា៖

ក. សហគ្រាសដែលមានផលរបររប្រចាំឆ្នាំលើសពី ៤ 000 លានរៀល ឬ

ខ. បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនពហុជាតិ សាខាក្រុមហ៊ុនបរទេស ឬ

គ. សហគ្រាសដែលបានចុះបញ្ជីជាគម្រោងវិនិយោគដែលមានលក្ខណ សម្បត្តិគ្រប់គ្រាន់។

## ៣. កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យធ្វើសវនកម្មគណនេយ្យ

❖ សហគ្រាសគ្រប់ប្រភេទមានកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឱ្យសវនករឯករាជ្យធ្វើសវនកម្ម ប្រសិនបើ៖

- សហគ្រាសស្ថិតនៅក្នុងលក្ខណវិនិច្ឆ័យ២ ក្នុងចំណោម៣ : (១)ផលរបរ ≥ ៣ពាន់លានរៀល (២)ទ្រព្យសកម្ម ≥ ២ពាន់លានរៀល និង(៣)ចំនួនបុគ្គលិក ≥១០០នាក់ ឬ
- សហគ្រាសដែលចុះបញ្ជីជាគម្រោងវិនិយោគដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ (គលក)។

*(ប្រកាសលេខ ៦៤៣ សហវ ប្រក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៧)*

# ៣. ភាគព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យធ្វើសវនកម្មគណនេយ្យ (ត)

- សហគ្រាសឧស្សាហកម្មផ្នែកវាយនភណ្ឌកាត់ដេរ ទទួលបានការអនុគ្រោះឱ្យព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល **រហូតដល់ដំណាច់ឆ្នាំ២០២២** ត្រូវផ្សារភ្ជាប់ជាមួយនឹងអនុលោមភាពសារពើពន្ធស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារដូចខាងក្រោម៖
  - កាន់កាប់បញ្ជិកាគណនេយ្យឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ និងបទប្បញ្ញត្តិនៃច្បាប់ស្តីពីគណនេយ្យជាធរមាន
  - ប្រកាសបង់ពន្ធអាករដទៃទៀតជាធរមានទៅតាមកាលកំណត់ និង
  - ផ្តល់របាយការណ៍សវនកម្មឯករាជ្យប្រចាំឆ្នាំជូនរដ្ឋបាលសារពើពន្ធ។

*(ប្រកាសលេខ ១១៣០ សហវ ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧)*

# ៤. សេចក្តីជូនដំណឹងស្តីពីការកែតម្រូវបញ្ជិកាគណនេយ្យនិងលិខិតប្រកាសពន្ធ ដោយស្ម័គ្រចិត្ត និងកាតព្វកិច្ចផ្តល់របាយការណ៍សវនកម្មឯករាជ្យ

- សហគ្រាសឧស្សាហកម្មផ្នែកវាយនភណ្ឌកាត់ដេរ ត្រូវមកធ្វើការកែតម្រូវឱ្យបានត្រឹមត្រូវនូវបញ្ជិកាគណនេយ្យ និងលិខិតប្រកាសពន្ធ ក្នុងរយៈពេល ០៣ (បី) ឆ្នាំថយក្រោយ និងផ្តល់របាយការណ៍សវនកម្មឯករាជ្យប្រចាំឆ្នាំ ជូនរដ្ឋបាលសារពើពន្ធឱ្យបានយ៉ាងយឺតបំផុតត្រឹម ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩។

*(សេចក្តីជូនដំណឹងលេខ ១២៨០២ អពដ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨)*

# ៥. ពន្ធអប្បបរមា និងលក្ខណវិនិច្ឆ័យនៃការកាន់បញ្ជិកាគណនេយ្យ មិនត្រឹមត្រូវនិងនីតិវិធីនៃការបង់ពន្ធអប្បបរមា

- ពន្ធអប្បបរមាត្រូវកំណត់ស្មើនឹង ១ ភាគរយ នៃផលរបរប្រចាំឆ្នាំរួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម។ ពន្ធអប្បបរមាត្រូវបង់សម្រាប់ឆ្នាំជាប់ពន្ធណាមួយ អាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណូលដែលបង់ជាក់ស្តែង ក្នុងឆ្នាំជាប់ពន្ធនោះ តាមវិធានដែលចែងក្នុងមាត្រា៣៧ថ្មី មាត្រា៣៨ និងមាត្រា៣៩ នៃច្បាប់ស្តីពីសារពើពន្ធ។
- ពន្ធអប្បបរមាត្រូវបានកំណត់លើសហគ្រាសទាំងឡាយណា **ដែលមិនកាន់បញ្ជិកាគណនេយ្យបានត្រឹមត្រូវ។**

# ៥. ពន្ធអប្បបរមា និងលក្ខណវិនិច្ឆ័យនៃការកាន់បញ្ជិកាគណនេយ្យ មិនត្រឹមត្រូវនិងនីតិវិធីនៃការបង់ពន្ធអប្បបរមា (ត)

- ពាក្យ "បញ្ជិកាគណនេយ្យ" សំដៅដល់សំណុំបញ្ជីគណនេយ្យ និងកំណត់ត្រាស្របតាមការតម្រូវរបស់អគ្គនាយកដ្ឋានពន្ធដារ និងស្របតាមស្តង់ដារគណនេយ្យដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- លក្ខណវិនិច្ឆ័យនៃការកាន់បញ្ជិកាគណនេយ្យមិនត្រឹមត្រូវ មានដូចខាងក្រោម៖
  - មិនបានកត់ត្រាបញ្ជីគណនេយ្យបានគ្រប់គ្រាន់តាមលក្ខខណ្ឌ
  - មិនបានចេញវិក្កយបត្រលើកិច្ចការជំនួញ ដូចមានចែងក្នុងមាត្រា៧៧ មាត្រា៧៨ មាត្រា៧៩ និងមាត្រា៩៨ នៃច្បាប់ស្តីពីសារពើពន្ធ។

*(ប្រកាសលេខ៦៣៨ សហវ.ប្រក ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧)*

# ៥. ពន្ធអប្បបរមា និងលក្ខណវិនិច្ឆ័យនៃការកាន់បញ្ជិកាគណនេយ្យមិនត្រឹមត្រូវនិងនីតិវិធីនៃការបង់ពន្ធអប្បបរមា (ត)

- បានប្រព្រឹត្តការធ្វេសប្រហែសធ្ងន់ធ្ងរ ដូចមានចែងក្នុងមាត្រា១២៦ នៃច្បាប់ស្តីពីសារពើពន្ធ
- បានធ្វើការគេចវេះពន្ធ ដូចមានចែងក្នុងមាត្រា១២៧ នៃច្បាប់ស្តីពីសារពើពន្ធ
- គ្មានរបាយការណ៍សវនកម្មរបស់សវនករឯករាជ្យ ក្នុងករណីសហគ្រាសដែលមានផលរបរលើសពី ២ ០០០ លានរៀលក្នុងមួយឆ្នាំ។

*(ប្រកាសលេខ៦៣៨ សហវ.ប្រក ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧)*

# ៦. ចំណាត់ថ្នាក់នៃអនុលោមភាពសារពើពន្ធ

## ❖ លក្ខណវិនិច្ឆ័យចំណាត់ថ្នាក់អនុលោមភាពសារពើពន្ធរបស់អ្នកជាប់ពន្ធ៖

| ល.រ | លក្ខណវិនិច្ឆ័យ | ពិន្ទុ |
|---|---|---|
| ១ | បានចុះបញ្ជីពន្ធដារ និងបច្ចុប្បន្នភាពការចុះបញ្ជី | ១ |
| ២ | បានជូនដំណឹងពីការផ្លាស់ប្តូរព័ត៌មាននៃការចុះបញ្ជី | ១ |
| ៣ | បានដាក់លិខិតប្រកាសសារពើពន្ធទៀងទាត់តាមកាលកំណត់ | ១ |
| ៤ | បានបង់ប្រាក់ពន្ធដែលបានប្រកាសគ្រប់ចំនួនតាមកាលកំណត់ | ១ |
| ៥ | បានកាន់កាប់បញ្ជិគណនេយ្យ លិខិតយុត្តិការ និងឯកសារផ្សេងៗ | ២ |
| ៦ | បានចេញវិក្កយបត្រត្រឹមត្រូវលើរាល់ប្រតិបត្តិការតាមច្បាប់និងបទប្បញ្ញត្តិ | ២ |
| ៧ | មិនបានប្រព្រឹត្តអំពើឆ្វេសប្រហែសដូចមានចែងក្នុងមាត្រា១២៥នៃ ច.ស.ព | ២ |

# ៦. ចំណាត់ថ្នាក់នៃអនុលោមភាពសារពើពន្ធ (ត)

| ល.រ | លក្ខណវិនិច្ឆ័យ | ពិន្ទុ |
|---|---|---|
| ៨ | មិនបានព្រឹត្តអំពើឆ្វេសប្រហែសធ្ងន់ធ្ងរដូចមានចែងក្នុងមាត្រា១២៦នៃ ច.ស.ព | ២ |
| ៩ | បានបង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗដែលរដ្ឋបាលសារពើពន្ធបានកំណត់ពន្ធ | ២ |
| ១០ | មិនបានកសាង ឬផ្តល់កំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានក្លែងបន្លំផ្សេងៗ | ២ |
| ១១ | បានផ្តល់កិច្ចសហការនិងអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធពិនិត្យបញ្ជីគណនេយ្យ ឬឯកសារផ្សេងៗ | ២ |
| ១២ | មិនត្រូវបានរកឃើញថាបានអនុវត្តការផ្ទេរថ្លៃរវាងបុគ្គលទាក់ទិន។ | ២ |

| ពិន្ទុសរុប | ប្រភេទចំណាត់ថ្នាក់អ្នកជាប់ពន្ធ |
|---|---|
| ១៦ ដល់ ២០ | មាស |
| ១១ ដល់ ១៥ | ប្រាក់ |
| ១ ដល់ ១០ | សំរិទ្ធ |

# ៦. ចំណាត់ថ្នាក់នៃអនុលោមភាពសារពើពន្ធ (ត)

| ពិន្ទុសរុប | ប្រភេទចំណាត់ថ្នាក់អ្នកជាប់ពន្ធ | អត្ថប្រយោជន៍ |
|---|---|---|
| ១៦ ដល់ ២០ | មាស | សុពលភាព២ឆ្នាំ, បង្វិលសងអតបក្រោម៥០០លានរៀលមុនធ្វើសវនកម្មផ្ទៀងផ្ទាត់, សវនកម្មពេញលេញ២ឆ្នាំម្តង ដោយគ្មានសវនកម្មមានកម្រិតនិងលើលិខិតស្នាម |
| ១១ ដល់ ១៥ | ប្រាក់ | សុពលភាព២ឆ្នាំ, បង្វិលសងអតបក្រោម២០០លានរៀលមុនធ្វើសវនកម្មផ្ទៀងផ្ទាត់, សវនកម្មពេញលេញ២ឆ្នាំម្តង សវនកម្មមានកម្រិត១ឆ្នាំម្តង ដោយគ្មានសវនកម្មលើលិខិតស្នាម |
| ១ ដល់ ១០ | សំរិទ្ធ | |

# ៧. ទោសទណ្ឌល្មើសបទប្បញ្ញត្តិស្តីពីពន្ធដារ

| បទល្មើសបទប្បញ្ញត្តិស្តីពីពន្ធដារ | | ពិន័យ និងទោសទណ្ឌ |
|---|---|---|
| ▪ ការធ្វេសប្រហែស | - ការធ្វេសប្រហែស (មាត្រា ១២៥)៖<br>▪ ប្រាក់ពន្ធបង់ខ្វះ ≤ ១០% នៃប្រាក់ពន្ធត្រូវបង់តាមច្បាប់ពន្ធដារ<br>▪ មិនបានដាក់លិខិតប្រកាសសារពើពន្ធ ឬមិនបានបង់ពន្ធតាមកាលបរិច្ឆេទដែលច្បាប់បានកំណត់។ | ▪ ពន្ធបន្ថែម ១០% នៃប្រាក់ពន្ធបង់យឺតឬខ្វះ<br>▪ ការប្រាក់ ២% ក្នុងមួយខែ |
| | - ការធ្វេសប្រហែសធ្ងន់ធ្ងរ (មាត្រា ១២៦)៖<br>▪ ប្រាក់ពន្ធបង់ខ្វះ > ១០% នៃប្រាក់ពន្ធត្រូវបង់តាមច្បាប់ពន្ធដារ | ▪ ពន្ធបន្ថែម ២៥% នៃប្រាក់ពន្ធបង់ខ្វះ<br>▪ ការប្រាក់ ២% ក្នុងមួយខែ |

# ៧. ទោសទណ្ឌលើសបទប្បញ្ញត្តិស្តីពីពន្ធដារ (ត)

**បទល្មើសបទប្បញ្ញត្តិស្តីពីពន្ធដារ**

- **ការគេចវេសពន្ធ**
  - បទល្មើសដោយចេតនាដោយដឹងជាមុន មានការរៀបចំទុក និងច្រើនដងទៅលើបទប្បញ្ញត្តិស្តីពីពន្ធដារ ក្នុងបំណងបន្ថយ ឬបំបាត់ប្រាក់ពន្ធដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវឱ្យបង់។
  - ល្មើសមាត្រា១២៧ ធ្វេសប្រហែសធ្ងន់ធ្ងរ ២លើក ដាច់ពីគ្នាយៈពេល ៣ឆ្នាំ នៃឆ្នាំប្រតិទិន។
  - ល្មើសមាត្រា១២៧ ធ្វេសប្រហែសធ្ងន់ធ្ងរ ៣លើក ឬច្រើនជាងនេះ ដាច់ពីគ្នាក្នុងរយៈពេលណាមួយក៏ដោយ។

**ពិន័យ និងទោសទណ្ឌ**

- ការកំណត់ពន្ធឡើងវិញ
  - ពន្ធបន្ថែម ២៥% នៃប្រាក់ពន្ធបង់ខ្វះ
  - ការប្រាក់ ២% ក្នុងមួយខែ
- ការកំណត់ពន្ធឯកតោភាគី
  - ពន្ធបន្ថែម ៤០% នៃប្រាក់ពន្ធបង់ខ្វះ
  - ការប្រាក់ ២% ក្នុងមួយខែ

- ទោសទណ្ឌព្រហ្មទណ្ឌ
  - អភិបាល បណ្ណាធិការ កម្មសិទ្ធិករ ឬបុគ្គលទទួលខុសត្រូវ បានប្រព្រឹត្តអំពើគេចវេសពន្ធ ត្រូវរងការផ្តន្ទាទោសពិន័យជាប្រាក់ពី**១០ លាន រៀល ដល់ ២០ លានរៀល ឬជាប់ពន្ធនាគារពី ១ ឆ្នាំ ដល់ ៥ ឆ្នាំ ឬ ទោសទាំងពីរនេះ។**

# ៧. ទោសទណ្ឌលើសបទប្បញ្ញត្តិស្តីពីពន្ធដារ (ត)

## កំហុសឆ្គងចាត់ទុកជាអំពើរាំងស្ទះ

**អំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ មាត្រា ១២៨**

- ✓ មិនបានរក្សាបញ្ជីការគណនេយ្យ និងឯកសារផ្សេងទៀតឬមិនចេញវិក្កយប័ត្រលើកិច្ចការជំនួញ
- ✓ មិនអនុញ្ញាត្តិឲ្យរដ្ឋបាលសារពើពន្ធធ្វើការពិនិត្យបញ្ជីការគណនេយ្យ និងឯកសារផ្សេងទៀត
- ✓ មិនបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ
- ✓ មិនបានជូនដំណឹងរដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្តូរក្នុងការចុះបញ្ជី
- ✓ កសាង ឬផ្តល់កំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានក្លែងបន្លំ
- ✓ លាក់ទុក ឬបំផ្លាញដោយចេតនានូវបញ្ជីការគណនេយ្យ កំណត់ត្រា ឯកសាររបាយការណ៍ ឬព័ត៌ផ្សេងទៀត
- ✓ ព្យាយាមធ្វើឲ្យរាំងស្ទះដល់ការកំណត់ពន្ធ និងការប្រមូលពន្ធ
- ✓ មិនដាក់លិខិតប្រកាសសារពើពន្ធដែលគ្មានប្រាក់ ពន្ធត្រូវបង់ក្នុងរយៈពេល៣០ថ្ងៃ ក្រោយកាលបរិច្ឆេទ ច្បាប់កំណត់
- ✓ ជួយជ្រោមជ្រែងដោយចេតនាដល់អំពើទាំងឡាយខាងលើ

## -ទោសទណ្ឌ (ពន្ធបន្ថែម)

២,០០០,០០០ រៀល
ចំពោះអ្នកជាប់ពន្ធឬភ្នាក់ងារកាត់ទុកជាប់ពន្ធរបបពិត
(ស្វ័យប្រកាស)

**- ទោសទណ្ឌព្រហ្មទណ្ឌ**
(មាត្រា ១៣៦)

# សូមអរគុណ